**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

SOCIAL PROTECTION IN CAMBODIA
គាំពារសង្គមកម្ពុជា

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៧)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតដែលបានព្យួរកិច្ចសន្យាការងារក្នុងខែកក្កដា និងខែសីហា ឆ្នាំ២០២៣ នៃរោងចក្រ ទាំង៣០ នៃវិស័យវាយនភណ្ឌ កាត់ដេរ ផលិត ស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃសេចក្តីណែនាំលេខ០២០/២៣ ក.ប/ ស.ណ.ន.ខ.ល ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣ ស្តីពីការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតធ្វើការនៅរោងចក្រក្នុងវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរនិងកាបូប ដែលរងផលប៉ះពាល់ដោយសារវិបត្តិសេដ្ឋកិច្ចសកល ជ្រាបថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរសព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួន៖
- ៨១ ០០០រៀល (២០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១៤ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១៥ថ្ងៃ ដល់ ១ខែ។

ក្រសួងសូមរំឭកថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខាន មិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ២១ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរសព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រទាំង៣០ នេះ មិនបានទទួលសារទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរសព្ទរបស់ខ្លួនទៅរដ្ឋបាលរោងចក្ររបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មករនិយោជិតរោងចក្រដទៃផ្សេងទៀត ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃពុធ ១០រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ខែតុលា ឆ្នាំ២០២៣

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

**ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី២៧ខែកញ្ញា ឆ្នាំ២០២៣**

**បញ្ជីឈ្មោះ រោងចក្រ ក្នុងវិស័យកាត់ដេរ**

**ចំនួន ៣០ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល**

| ល.រ | ឈ្មោះរោងចក្រ | រាជធានី ខេត្ត |
|---|---|---|
| វិស័យកាត់ដេរ | | 30 |
| 1 | ក្រុមហ៊ុន អ៊ីហ្ស៊ី ឡាហ្វ៍ ស៊ូ អិលធីឌី | ភ្នំពេញ |
| 2 | ក្រុមហ៊ុន សាន់តិច ភីធីអ៊ី អ៊ិលធីឌី | ភ្នំពេញ |
| 3 | ក្រុមហ៊ុន អិកស៍អូចិច អ៊ិនដាសស្រ្ទៀល ឯ.ក | ភ្នំពេញ |
| 4 | ក្រុមហ៊ុន ស៊ីកូ(ភ្នំពេញ)ខូអិលធីឌី | ភ្នំពេញ |
| 5 | ក្រុមហ៊ុន យីងសិនសេងព្រីនធីង ឯ.ក | ភ្នំពេញ |
| 6 | ក្រុមហ៊ុន ផាភីលៀន ថេកស្ទាយ (ខេមបូឌា)ខូអិលធីឌី | ភ្នំពេញ |
| 7 | ក្រុមហ៊ុន ហ្វ៊ូរឈូន ប្រត ហ្វ៊ូតវែរ ឯ.ក(ភ្នំពេញ) | ភ្នំពេញ |
| 8 | ក្រុមហ៊ុន ហេន ស៊ើវេន អឺភែរឹល | ភ្នំពេញ |
| 9 | ក្រុមហ៊ុន ហេន7 ហ្គាម៉ិនឯក (ទីតាំងពោធិ៍សែនជ័យ) | ភ្នំពេញ |
| 10 | ក្រុមហ៊ុន ជេអេដាប់បែលយូ ( J.A.W ) | ភ្នំពេញ |
| 11 | ក្រុមហ៊ុន សេអ៊ីល (ខេមបូឌា) | ភ្នំពេញ |
| 12 | ក្រុមហ៊ុន ខ្វាន់ទុម ខ្លូស៊ីង (ខេមបូឌា) លីមីតធីត | ភ្នំពេញ |
| 13 | ក្រុមហ៊ុន វីងយីង(ខេមបូឌា)ហ្គាមេនហ្វាក់ធើរី អិលធីឌី | កណ្តាល |
| 14 | ក្រុមហ៊ុន គ័ន ម៉ីង ហ៊ែនប៉ែក (ខេមបូឌា) អ៊ិនដាសស្រ្ទៀល ឯ.ក | កណ្តាល |
| 15 | ក្រុមហ៊ុន ម៉ាស្ទ័រ&ប្រៀង(ខេមបូឌា)ខូអិលធីឌី | កណ្តាល |
| 16 | ក្រុមហ៊ុន វីង ស្តារ ស៊ូ | កំពង់ស្ពឺ |
| 17 | ក្រុមហ៊ុន ហ៊ុង ហ៊ីង មេធល មេនូហ្វេធើរី (ខេមបូឌា) ឯ.ក | កំពង់ស្ពឺ |
| 18 | ក្រុមហ៊ុន ស៊ីអិនឌីហ្វ្រី អិនធើណេសិនណល (ខេអេច) ឯ.ក | កំពង់ស្ពឺ |
| 19 | ក្រុមហ៊ុន យូនីប្រូស(ខេមបូឌាអេន)ធើប្រាយ ខូ អិល ធី ឌី | កំពង់ស្ពឺ |
| 20 | ក្រុមហ៊ុន ហេង ស៊ីម ហ្វ៊ូត វែរ ឯ.ក | កំពង់ស្ពឺ |

| ល.រ | ឈ្មោះរោងចក្រ | រាជធានី ខេត្ត |
|---|---|---|
| 21 | ក្រុមហ៊ុន តាកែវស៊ូ (ខេមបូឌា) ខូ.,អិលធីឌី | តាកែវ |
| 22 | ក្រុមហ៊ុន ប្រាយ ហ្គាស់ស៊ីង ឯ.ក | តាកែវ |
| 23 | ក្រុមហ៊ុន អៅដរ ហ្គៀ (ខេមបូឌា) ឯ.ក | តាកែវ |
| 24 | ក្រុមហ៊ុន ប៉ុនតឹសហ្វិតវែរ អិល ធី ឌី | តាកែវ |
| 25 | ក្រុមហ៊ុន ជូនលី អ៊ិនធើណេសិនណល ឯ ក | តាកែវ |
| 26 | ក្រុមហ៊ុន វ៉ាយស៍ ស្ទីឌី ហ្វូដវែរ មេធៀរៀល (ខេមបូឌា) ឯ.ក | កំពង់ចាម |
| 27 | ក្រុមហ៊ុន សាន់ ស៊ូ ហ្គាមិន ខូអិលធីឌី | កំពង់ចាម |
| 28 | ក្រុមហ៊ុន ខេន ស្តែត ស៊ូ | កំពង់ឆ្នាំង |
| 29 | ក្រុមហ៊ុន ស៊ុនស៊ីនឡាក់ហ្គេដអ៊ីនដាសស្ទ្រី(ខេមបូឌា) | កំពង់ឆ្នាំង |
| 30 | ក្រុមហ៊ុន ហ៊ែលសា សៅអ៊ិសអេស៊ា ខូអិលធីឌី | ស្វាយរៀង |